

# គម្រោង អិលធីស៊ី ដំណាក់កាលទី២
## ព័ត៌មានសង្ខេប

© Mao Daravuthy / WWF-Cambodia

## សារតាគម្រោង

**គម្រោង អិលធីស៊ីដំណាក់កាលទី១: ២០១៨-មិថុនា ឆ្នាំ ២០២៣**
**គម្រោង អិលធីស៊ីដំណាក់កាលទី២: កក្កដា ២០២៣-កញ្ញា ឆ្នាំ ២០២៥**






### គោលបំណងរបស់គម្រោង

អិលធីស៊ីដំណាក់កាលទី២ ជាកម្មវិធីសាកលបានចាប់ផ្តើមបន្តពីដំណាក់កាលទី១ កាលពី ខែកក្កដា ឆ្នាំ២០២៣ ដែលមានគោលបំណង ដើម្បីគាំទ្រដល់ការរីកចម្រើនជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ដែលយើងទាំងអស់គ្នាអាចរីករាយនឹងបរិស្ថាន ប្រកបដោយសុវត្ថិភាព ភាពស្អាត មានសុខភាពល្អ និងនិរន្តរភាព។



© Koulang Chey / WWF-Cambodia

នៅក្នុងប្រទេសកម្ពុជា គម្រោងនេះជាបានផ្តល់ជំនួយហិរញ្ញប្បទានដល់អង្គការសង្គមស៊ីវិល ចំនួន៥ ដើម្បីលើកកម្ពស់ស្ថាប័នរបស់ខ្លួន ព្រមទាំងសិទ្ធិរបស់ពួកគេក្នុងការចូលរួម និងការការពារជីវៈចម្រុះ បង្ហាញពីការអនុវត្តល្អៗ ដូចជាជីវភាពរស់នៅបានប្រសើរ និងចូលរួមដល់គោលនយោបាយក្នុងការគ្រប់គ្រងធនធានធម្មជាតិ។

## មូលហេតុ និងបរិបទគម្រោង

កង្វះខាតក្នុងការគ្រប់គ្រងប្រពន្ធអេកូឡូស៊ី បានបណ្តាលឱ្យប៉ះពាល់ដល់ធម្មជាតិ និងប្រជាជន ជាពិសេសនៅតំបន់ងាយរងគ្រោះ ។ ការលើកម្ពស់សិទ្ធិ របស់សហគមន៍មូលដ្ឋាន ដើម្បីចូលរួមក្នុងការសម្រេចចិត្ត សិទ្ធិរបស់ពួកគេទទួលបាន និងគ្រប់គ្រងធនធានប្រកបដោយនិរន្តរភាព ប្រែក្លាយពួកគេទៅជាភ្នាក់ងារសំខាន់នៃការផ្លាស់ប្តូរ ជម្រុញការការពារបរិស្ថាន សមធម៌សង្គម និងធម្មជាតិដើម្បីអនាគតវិជ្ជមាន ។

## ធាតុសំខាន់ៗរបស់គម្រោង

សិទ្ធិរបស់សហគមន៍មូលដ្ឋាន ត្រូវបានទទួលស្គាល់ ហើយក្រុមពួកគេទទួលបានការទទួលខុសត្រូវពីស្ថាប័នពាក់ព័ន្ធ ទាក់ទងនឹងសិទ្ធិគ្រប់គ្រងដីសហគមន៍ ឬធនធានក្នុងសហគមន៍ និងការចូលរួមនានា។

**ឆ្នាំ ២០១៨**
ផ្តល់ជំនួយហិរញ្ញប្បទានដល់អង្គការសង្គមស៊ីវិល ចំនួន១ និងសហគមន៍មូលដ្ឋានចំនួន ៥

**ឆ្នាំ ២០១៩**
ផ្តល់ជំនួយហិរញ្ញប្បទានដល់អង្គការសង្គមស៊ីវិល ចំនួន១ និងសហគមន៍មូលដ្ឋានចំនួន ១៦

**ឆ្នាំ ២០២០**
ផ្តល់ជំនួយហិរញ្ញប្បទានដល់អង្គការសង្គមស៊ីវិល ចំនួន១ និងសហគមន៍មូលដ្ឋានចំនួន ១៧

**ឆ្នាំ ២០២១**
ផ្តល់ជំនួយហិរញ្ញប្បទានដល់អង្គការសង្គមស៊ីវិល ចំនួន១ និងសហគមន៍មូលដ្ឋានចំនួន ១៨

**ឆ្នាំ ២០២២**
ផ្តល់ជំនួយហិរញ្ញប្បទានដល់អង្គការសង្គមស៊ីវិល ចំនួន១ និងសហគមន៍មូលដ្ឋានចំនួន ២៣

**ឆ្នាំ ២០២៣-២០២៥**
ផ្តល់ជំនួយហិរញ្ញប្បទានដល់អង្គការសង្គមស៊ីវិល ចំនួន៤ និងបណ្តាញសហគមន៍ព្រៃឈើចំនួន ១

## ដំណើការរបស់គម្រោង

គម្រោងនេះ យកភាពជាដៃគូជាយុទ្ធសាស្រ្ត ការទទួលស្គាល់សិទ្ធិជាមូលដ្ឋាន និងការអភិរក្សរួមគ្នា ដើម្បីលើកកម្ពស់សហគមន៍មូលដ្ឋាន។ ជាមួយគ្នានេះដែរ ការទទួលបានការប្រើប្រាស់ធនធានដោយសមធម៌ លើកម្ពស់គុណតម្លៃរួម និងការកាពារជីវៈចម្រុះប្រកបដោយនិរន្តរភាព ផ្តល់អត្ថប្រយោជន៍ទាំងមនុស្ស និងធម្មជាតិ។

## តំបន់គោលដៅ

**តំបន់ទេសភាពខ្ពង់រាបភាគខាងកើត (ខេត្តមណ្ឌលគិរី)**
**តំបន់ទេសភាពព្រៃលិចទឹកមេគង្គ (ខេត្តក្រចេះ)**
**តំបន់ឆ្នេរ៖**
- ខេត្តកំពត
- ខេត្តកោះកុង
- ខេត្តព្រះសីហនុ





## សូមទំនាក់ទំនងមកកាន់៖

**WWF-Cambodia:**
Chea Chan Neuv
Senior Project Officer
channeuv.chea@wwf.org.kh
wwfcambodia@wwf.org.kh
website: wwf.org.kh

**WWF Sweden:**
Keiko Nagano
Programme Manager Civil Society
keiko.nagano@wwf.se




© Koulang Chey / WWF-Cambodia